បេឡាជាតិរបបសន្តិសុខសង្គម
National Social Security Fund

# ព្រឹត្តិបត្រព័ត៌មានបេឡាជាតិសន្តិសុខសង្គម

## ប.ស.ស ឆ្នាំទី ១០
## លេខ ២៦ ឆ្នាំ ២០១៩





ទំនាក់ទំនងបន្ទាន់
១២៨៦
២៤ម៉ោង/៧ថ្ងៃ

លើកកម្ពស់ស្ថិរភាពសង្គម
រួមចំណែកកាត់បន្ថយភាពក្រីក្រ
ធានាសន្តិសុខប្រាក់ចំណូល

ព្រឹត្តិបត្រព័ត៌មាន

# ប.ស.ស

## មាតិកា


០១ ព្រះករុណា ព្រះមហាក្សត្រយាងជាព្រះរាជវត្តមានដ៏មហា.........០១

០២ ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកបេឡា.......០៣

០៣ ក្រុមប្រឹក្សាជាតិគាំពារសង្គម បើកកិច្ចប្រជុំពិភាក្សា ស្តីពី...........០៥

០៤ ឯកឧត្តមបណ្ឌិត អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និង........០៧

០៥ ប្រធាន អនុប្រធាន និងមន្ត្រី ប.ស.ស សរុបប្រមាណជាង.......០៩

០៦ ពិធីសូត្រមន្តប្រោះព្រំលើករាសី សុំសិរីសួស្តី ជ័យមង្គលវិបុល....១០

០៧ ប្រធាន អនុប្រធាន និងមន្ត្រីទទួលបន្ទុកសាខា ប.ស.ស..........១១

០៨ ប្រធានអង្គភាពធានារ៉ាប់រងសុខភាពជាតិ នៃសាធារណរដ្ឋកូរ៉េ....១៣

០៩ បច្ចុប្បន្នវិស័យសេដ្ឋកិច្ចកម្ពុជាមានការរីកចម្រើន ក្នុងនោះក៏......១៥

១០ គ្រោះថ្នាក់ចរាចរណ៍នៅតែជាកង្វល់ដ៏ធ្ងន់ធ្ងរមួយរបស់រាជរដ្ឋា.....១៩

១១ ក្រុមការងារ ប.ស.ស សហការជាមួយរដ្ឋបាលខេត្តប៉ៃលិន.......២១

១២ កិច្ចប្រជុំស្តីពីការបង្ហាញលទ្ធផលបឋម និងពិគ្រោះយោបល់.....២៣

១៣ មន្ត្រីជំនាញ នៃបេឡាជាតិរបបសន្តិសុខសង្គម ចូលរួម..........២៥

១៤ កិច្ចប្រជុំស្តីពី "ការយល់ដឹងពីប្រព័ន្ធគាំពារសង្គមសម្រាប់កម្មករ..២៦

១៥ មន្ត្រីជំនាញនៃ ប.ស.ស ចំនួន៨រូប ចូលរួមកិច្ចប្រជុំផ្លាស់ប្តូរ.....២៧

១៦ កិច្ចប្រជុំក្រុមការងារបច្ចេកទេស SPIN ស្តីពីការធ្វើបទបង្ហាញ..២៨

១៧ កូនមាសឪពុក (លោកគ្រូអគ្គបណ្ឌិត ធម្មាចារ្យ ប៊ុត សាវង្ស).....៣០

១៨ ចេក ងាយរកនិងមានតម្លៃសមរម្យប៉ុន្តែផ្តល់អត្ថប្រយោជន៍.......៣១









## រចនាសម្ព័ន្ធព្រឹត្តិបត្រ

**ឯកឧត្តម អ៊ុក សមវិទ្យា**
**នាយក ប.ស.ស**

**ចាងហ្វាង** ឯកឧត្តម **ហេង សុផាន់ណារិទ្ធ**
**និពន្ធនាយក** លោក **យ៉ាម យុទ្ធា**
**និពន្ធនាយករង** លោក **ឃុន វិចិត្រ**
លោក **ទ៉ាន់ ចាន់ថន**
**លេខានិពន្ធ** កញ្ញា **រ៉ាត់ ម៉ាលីកា**
លោក **នាង ជូ**
លោក **យន គន្ធា**
លោក **អ៊ុំ លាងឆុង**
លោក **លឹម តក់**
**ផ្នែកការីកុំព្យូទ័រ** លោក **ប៊ុត ស៊ីម**
លោក **យង់ សុខន**
លោក **អ៊ុំ ស៊ីខឿ**

# អង្គការលេខរបស់បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស)





# ព្រះករុណា ព្រះមហាក្សត្រយាងជាព្រះរាជវត្តមានដ៏មហាវិសេសវិសាល ក្នុងព្រះរាជពិធីបុណ្យច្រត់ព្រះនង្គ័ល នៅខេត្តតាកែវ

ព្រះករុណា ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តមសីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា នៅព្រឹកថ្ងៃពុធ ៤រោច ខែពិសាខ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៩ បានយាងជាព្រះរាជវត្តមានដ៏មហាវិសេសវិសាល ក្នុងព្រះរាជពិធីបុណ្យច្រត់ព្រះនង្គ័ល នៅខេត្តតាកែវ។

ព្រះរាជពិធីបុណ្យច្រត់ព្រះនង្គ័ល តែងតែប្រារព្ធធ្វើឡើងជារៀងរាល់ឆ្នាំនៅក្នុងខែពិសាខ នៅឯវាលព្រះមេរុ ស្ថិតនៅខាងជើង ព្រះបរមរាជវាំង នៃរាជធានីភ្នំពេញ តែឆ្នាំខ្លះព្រះរាជពិធីនេះ ក៏មានធ្វើនៅតាមប ណ្តាខេត្តនានាផងដែរ ព្រះរាជពិធីមួយនេះមាន ប្រវត្តិដ៏យូរលង់ណាស់មកហើយ។ ព្រះរាជពិធីបុណ្យប្រពៃណីនេះ ធ្វើឡើងក្នុងគោលបំណងផ្សងមើលប្រផ្នូលរបស់ស្រុកទេស ទៅតាមការបរិភោគរបស់ «គោឧសភរាជ»។ ការប្រារព្ធព្រះរាជពិធីនេះក៏ជាការដាស់តឿន ក្រើនរំឭកដល់ប្រជាជនខ្មែរដែលពឹងផ្អែក លើការធ្វើកសិកម្មជាចម្បង ឱ្យបានដឹងថា រដូវវស្សាបានចូលមកដល់ហើយ។





បើតាមប្រវត្តិខ្លះៗ នៃព្រះរាជពិធីបុណ្យច្រត់ព្រះនង្គ័លបានឱ្យដឹងថា៖ ព្រះរាជពិធីបុណ្យច្រត់ព្រះនង្គ័ល ដែលត្រូវបានប្រារព្ធធ្វើឡើង ជារៀងរាល់ឆ្នាំ នៅក្នុងខែពិសាខ គឺជាព្រះរាជពិធីមួយសំខាន់បំផុត បន្ទាប់ពីព្រះរាជាអភិសេក ហើយក៏ជាព្រះរាជពិធីមួយ ស្ថិតក្នុងចំណោមព្រះរាជពិធីផ្សេងៗឯទៀតប្រចាំឆ្នាំ ដែលចាត់ចូលជាព្រះរាជពិធីទ្វារទសមាស។ នៅប្រទេសឥណ្ឌាបុរាណ និងនៅព្រះរាជាណាចក្រកម្ពុជា ការប្រកបរបរកសិកម្មជាមុខរបរចម្បង ដោយពឹងពាក់ទាំងស្រុងលើស្រូវអង្ករ និងភោគផលដំណាំដទៃៗទៀត (បច្ចុប្បន្នប្រជានុរាស្ត្រខ្មែរ ប្រកបមុខរបរធ្វើស្រែចម្ការពី ៨៣% ទៅ ៨៥%)។



ការបង្កើតផលិតផលស្រូវអង្ករ ឬក៏ផលដំណាំផ្សេងៗ ដូចជាពោត សណ្តែក ល្ង ដោយព្រះរាជាតាមរយៈព្រះរាជពិធីខាងលើនេះបណ្តាលមកពីកត្តាចម្បងមួយ គឺលក្ខណៈស័ក្តិសិទ្ធិរបស់តួអង្គ «ស្តេច» ក្នុងក្រសៃភ្នែករបស់ប្រជានុរាស្ត្រ។ មានន័យថា ផលដំណាំពុំមែន ស្ថិតនៅត្រឹមតែការដាំដុះ បច្ចេកទេស ឬសេដ្ឋកិច្ចនោះទេ ពោលគឺប្រាកដជាបណ្តាលមកពីពិធីកម្មនេះឯង។ តាមទម្លាប់ពិធីនេះធ្វើឡើងក្នុងការផ្សងមើលប្រផ្នូលរបស់ស្រុកទេស ទៅតាមការស៊ី ផឹក របស់ " គោឧសភរាជ "។ គោ១នឹម ដែលទឹមច្រត់ព្រះនង្គ័លនោះ គេហៅថា «គោឧសភរាជ» ក៏មានកំណត់ក្នុងលក្ខណៈតាមបែបនិយមបច្ចុប្បន្ន គឺសម្បុរខ្មៅ ស្នែងរាងជ្រពាស់ឈ្នក់ ឬ ប្រក់នាគ គឺរាងខុបទៅមុខបន្តិច ហើយវាត់ចុងទៅលើបន្តិច ។ គោ២ នឹមទៀត ដែលសម្រាប់ ហែរមុខហែរក្រោយឃើញថា មិនទាន់កំណត់លក្ខណៈ តែតាមដែលធ្លាប់ប្រើមក ហើយឃើញច្រើនតែសម្បុរក្រហម ។ ឯ «គោឧសភរាជ» នោះវេលាទឹមច្រត់ព្រះនង្គ័ល គេប្រដាប់ដោយគ្រឿង គឺពាក់ស្រោមមុខស្រោមស្នែង និងពាក់សំពត់កម្រាល សម្បុរក្រហមលើខ្នងផង។ ឯព្រះនង្គ័លទាំង៣នោះ គេលាបថ្នាំពណ៌ខ្មៅកាត់ខ្សែក្រហមដោយអន្លើៗឯចន្ទោលព្រះនង្គ័ល សម្រាប់អ្នកតំណាងព្រះអង្គនោះ មានលក្ខណៈពិសេសគឺធ្វើជារូបនាគ លាបថ្នាំពណ៌លឿងបែបយ៉ាងពណ៌មាស។ នៅត្រង់កនាគមានភួធ្វើពីរោមសត្វសម្បុរបែបភួទួន។ ទាក់ទិននឹងការផ្សងគោឧសភរាជ គឺព្រាហ្មណ៍ព្រះរាជគ្រូ សូត្រពាក្យអធិដ្ឋានផ្សងគោឧសភរាជ ដែលទឹមច្រត់ព្រះនង្គ័លនោះ ឱ្យស៊ីផឹកអាហារ៧យ៉ាង ដែលភ្នាក់ងាររៀបដាក់តុប្រាក់ធំៗ តាំងទុកនៅទីមុខព្រះពន្លា គឺគ្រាប់ស្រូវ១តុ គ្រាប់សណ្តែក១តុ គ្រាប់ពោត១តុ គ្រាប់ល្ង១តុ ស្មៅស្រស់១តុ ទឹក១តុ ស្រា១តុ ។ សូត្រចប់ព្រាហ្មណ៍ព្រះរាជគ្រូ យកទឹកមន្តប្រោះក្បាលព្រះគោទាំងពីរ ហើយមន្ត្រីម្នាក់ដែលកាន់នង្គ័លស្តេចមាឃ ដឹកគោឧសភរាជទាំងពីរទៅឱ្យស៊ីផឹករបស់ទាំង៧យ៉ាង គឺដឹកទៅជិតរបស់៧យ៉ាងស្រេចហើយ តែគោឧសភរាជចូលចិត្តស៊ីផឹកអ្វី ក៏ស៊ីផឹកទៅគេមិនបង្ខំឱ្យស៊ីផឹកចំពោះអាហារណានីមួយៗទេ កាលព្រះគោស៊ីផឹកអ្វីមួយយ៉ាង ឬពីរយ៉ាងព្រាហ្មណ៍ក៏ទាយផលប្រផ្នូលទៅខាងមុខតាមនោះប្រកាសផ្សាយ៕



# ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) អញ្ជើញចូលរួមកិច្ចប្រជុំបូកសរុបលទ្ធផលការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោក

នៅថ្ងៃអង្គារ ៥កើត ខែចេត្រ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី៩ ខែមេសា ឆ្នាំ២០១៩ ក្រសួងមហាផ្ទៃ បានរៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោក ប្រចាំត្រីមាសទី១ ឆ្នាំ២០១៩ នៅទីស្តីការក្រសួងមហាផ្ទៃ ក្រោមអធិបតីភាព **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក (គ.ស.ច.គ) ដោយមានការអញ្ជើញចូលរួមពីទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ អភិបាលនៃគណៈអភិបាលទាំង ២៥រាជធានី/ខេត្ត និងស្ថាប័នពាក់ព័ន្ធមួយចំនួន ដែលជាសមាជិកគណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោកប្រមាណជា ១៧០នាក់។



យោងតាមរបាយការណ៍របស់អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន គ.ស.ច.គ កន្លងមកបានសហការជាមួយក្រុមការងារ ប.ស.ស ដើម្បីផ្សព្វផ្សាយអប់រំច្បាប់ចរាចរណ៍ផ្លូវគោកដល់កម្មករនិយោជិត និងអ្នកបើកបររថយន្តដឹកកម្មករចំនួន ១៥៦លើក អ្នកបើកបរយានយន្តសរុប ៨ ៩៥៨នាក់ នៅរាជធានីខេត្តចំនួន១៤។ ទោះបីជាក្រុមការងារបានធ្វើការផ្សព្វផ្សាយអប់រំច្បាប់ចរាចរណ៍ផ្លូវគោកដល់អ្នកបើកបរយានយន្តជាច្រើនរួមមកហើយ តែហេតុការណ៍គ្រោះចរាចរណ៍ប្រចាំត្រីមាសទី១ ឆ្នាំ២០១៩ នៅតែបន្តកើតឡើងរហូតដល់ទៅចំនួន១០៧៦លើក បានបណ្តាលឱ្យមានអ្នកស្លាប់ចំនួន ៥១៣នាក់ និងរបួសចំនួន ១ ៥៩២នាក់។ រាជធានី/ខេត្តដែលមានអ្នកស្លាប់ច្រើនគឺរាជធានីភ្នំពេញចំនួន ៩១នាក់ ខេត្តកំពង់ស្ពឺចំនួន ៣៩នាក់ និងខេត្តព្រះសីហនុចំនួន ៣២នាក់។







មូលហេតុដែលនាំឱ្យគ្រោះថ្នាក់ចរាចរណ៍គឺ ៤១% ការបើកបរលើសល្បឿនកំណត់ ១៩% មិនគោរពសិទ្ធិ ១៣% មិនប្រកាន់ស្តាំ ៩% បត់ ៩% វ៉ាជែង ៤% ស្រវឹង ៣% កត្តាយានយន្តនិង ២% ងងុយ។ បើប្រៀបធៀបត្រីមាសទី១ (ឆ្នាំមុន) ឆ្នាំ២០១៨ គ្រោះថ្នាក់កើនចំនួន ២៥៧លើក (១ ០៧៦/៨១៩លើក) ស្មើ ៣១% ស្លាប់កើនចំនួន ៣៣នាក់ (៥១៣/៤៨០) ស្មើ៧% និងរបួសកើន ៣៥៨នាក់ (១ ៥៩២/១ ២៣៤នាក់) ស្មើ ២៩%៕







# ក្រុមប្រឹក្សាជាតិគាំពារសង្គម បើកកិច្ចប្រជុំពិភាក្សា ស្តីពីវឌ្ឍនភាពនៃការរៀបចំសេចក្តីព្រាងច្បាប់វឌ្ឍនភាពការងាររបស់បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស)

កិច្ចប្រជុំពិភាក្សារបស់ក្រុមប្រឹក្សាជាតិគាំពារសង្គម នៅថ្ងៃអង្គារ ៤រោច ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី ២៣ ខែមេសា ឆ្នាំ២០១៩ នេះត្រូវបានរៀបចំឡើងនៅសាលប្រជុំនៃទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រោមអធិបតីភាព **ឯកឧត្តម អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម ដែលមានសមាសភាពអញ្ជើញចូលរួមជាអាទិ៍៖ **ឯកឧត្តមបណ្ឌិត** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាល-វិជ្ជាជីវៈ **ឯកឧត្តម** រដ្ឋមន្ត្រីក្រសួងសុខាភិបាល **ឯកឧត្តម** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី នៃក្រុមប្រឹក្សាអភិវឌ្ឍកម្ពុជា **ឯកឧត្តម** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកបេឡាជាតិរបបសន្តិសុខសង្គម ឯកឧត្តម លោកជំទាវ លោក លោកស្រីដែលជាសមាសភាពនៃក្រុមប្រឹក្សាជាតិគាំពារសង្គម និងគណៈកម្មាធិការប្រតិបត្តិនៃក្រុមប្រឹក្សាជាតិគាំពារសង្គម ព្រមទាំងតំណាងក្រសួងស្ថាប័នពាក់ព័ន្ធនានាជាច្រើនទៀត។





សម្រាប់ខ្លឹមសារនៃកិច្ចពិភាក្សាគឺផ្តោតទៅលើវឌ្ឍនភាពសំខាន់ៗចំនួន៤ រួមមាន៖

- វឌ្ឍនភាពការងាររបស់បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស)
- វឌ្ឍនភាពនៃការរៀបចំសេចក្តីព្រាងច្បាប់ស្តីពី "របបសន្តិសុខសង្គម"
- វឌ្ឍនភាពនៃការរៀបចំដាក់ឱ្យអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ ជូនស្ត្រីមានផ្ទៃពោះ និងកុមារដែលមានអាយុក្រោម ២ឆ្នាំ បញ្ហាផ្សេងៗ៕











## ឯកឧត្តមបណ្ឌិត អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ កោតសរសើរ ចំពោះថ្នាក់ដឹកនាំ មន្ត្រីរាជការ និងបុគ្គលិក នៃបេឡាជាតិរបបសន្តិសុខសង្គម ក្នុងការបំពេញការងារនាឆ្នាំកន្លងមក

**ឯកឧត្តមបណ្ឌិត អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៅក្នុងឱកាសដ៏សោមនស្សរីករាយនៃពិធីពិសារអាហារសាមគ្គី និងអបអរពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ដែលបានប្រព្រឹត្តទៅនៅថ្ងៃសុក្រ ១កើត ខែចេត្រ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៩ នៅវិមានពិភពថ្មីសែនសុខ បានថ្លែងកោតសរសើរយ៉ាងខ្លាំងចំពោះថ្នាក់ដឹកនាំ មន្ត្រីរាជការ និងបុគ្គលិកទាំងអស់ នៃបេឡាជាតិរបបសន្តិសុខសង្គម ដែលបានខិតខំអស់ពីកំលាំងកាយចិត្ត និងយកចិត្តទុកដាក់ខ្ពស់បំផុតក្នុងការបំពេញការងាររបស់ខ្លួនកន្លងមកប្រកបដោយជោគជ័យគួរជាទីមោទកៈ ដើម្បីបម្រើសេវារបបសន្តិសុខសង្គមជូនបងប្អូនកម្មករនិយោជិតទាំងក្នុង និងក្រៅប្រព័ន្ធ ក្នុងការទទួលបានសេវាគាំពារសង្គមស្របតាមគោលនយោបាយជាតិគាំពារសង្គមរបស់រាជរដ្ឋាភិបាល។



**ឯកឧត្តមបណ្ឌិត** រដ្ឋមន្ត្រី បានបន្តថា៖ យើងទាំងអស់គ្នា នឹងពួតដៃរួបរួម ដើម្បី រួមចំណែកក្នុងការអភិវឌ្ឍន៍ប្រទេសជាតិ និងជាឧត្តមប្រយោជន៍សម្រាប់បុព្វហេតុជាតិមាតុភូមិកម្ពុជាដ៏បវរថ្លៃថ្លានៃយើងទាំងអស់គ្នាបន្តទៀត។

**ឯកឧត្តមបណ្ឌិត** រដ្ឋមន្ត្រីបានបន្តទៀតថា៖ អ្វីទាំងអស់នេះក៏ដោយសារប្រទេសជាតិមាន សុខសន្តិភាពពេញបរិបូណ៌ ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត និងភាពឈ្លាសវៃរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា តែងតែគិតគូរពីទុក្ខលំបាករបស់បងប្អូនប្រជាពលរដ្ឋ និងបងប្អូនកម្មករនិយោជិត និងធ្វើយ៉ាងណាឱ្យប្រទេសជាតិមានសុខសន្តិភាព សេរីភាព និងអភិវឌ្ឍន៍។

នៅក្នុងឱកាសនោះផងដែរ **ឯកឧត្តមបណ្ឌិត** រដ្ឋមន្ត្រីក៏បានជូនពរដល់ថ្នាក់ដឹកនាំ មន្ត្រីរាជការ និងបុគ្គលិកទាំងអស់នៃបេឡាជាតិរបបសន្តិសុខសង្គម ព្រមទាំងប្រជាពលរដ្ឋខ្មែរ ជាពិសេសកម្មករកម្មការិនី ធ្វើដំណើរទៅជួបជុំឪពុក ម្តាយ បងប្អូន និងសាច់ញាតិនៅឯស្រុកកំណើតវិញ សូមឱ្យជួបតែសេចក្តីសុខ សេចក្តីចម្រើន និងសូមឱ្យរីករាយសប្បាយទាំងអស់គ្នាក្នុងឱកាសជួបជុំគ្រួសារជាទីស្រឡាញ់និងសូមឱ្យអ្នកបើកបរទាំងអស់ចូលរួមគោរពច្បាប់ចរាចរណ៍ទាំងអស់គ្នា៕









# ប្រធាន អនុប្រធាន និងមន្ត្រី ប.ស.ស សរុបប្រមាណជាង ៥០នាក់ នៅតាមបណ្តាសាខាទូទាំងរាជធានី ខេត្ត-ខណ្ឌ ចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីបច្ចុប្បន្នភាពការងារជំនាញទាក់ទងនឹងរបបសន្តិសុខសង្គម

**ឯកឧត្តម អ៊ឹក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកបេឡាជាតិរបបសន្តិសុខសង្គម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៅក្នុងវគ្គបណ្តុះបណ្តាល ស្តីពីបច្ចុប្បន្នភាពការងារជំនាញទាក់ទងនឹងរបបសន្តិសុខសង្គម ដល់ប្រធាន អនុប្រធាន និងមន្ត្រី ប.ស.ស តាមបណ្តាសាខាទូទាំងរាជធានី ខេត្ត-ខណ្ឌ កាលពីថ្ងៃចន្ទ ១២រោច ខែផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២ ត្រូវនឹងថ្ងៃទី១ ខែមេសា ឆ្នាំ២០១៩ ដែលប្រព្រឹត្តទៅនៅសាលប្រជុំធំ នៃ ប.ស.ស ស្នាក់ការកណ្តាលរាជធានីភ្នំពេញ បានថ្លែងថា៖ គោលបំណងនៃវគ្គបណ្តុះបណ្តាលនេះ ដើម្បីបង្កើនសមត្ថភាព និងចែករំលែកចំណេះដឹង ក៏ដូចជាបទពិសោធន៍ថ្មីៗ ទាក់ទងនឹងការងារប្រចាំថ្ងៃ ឱ្យកាន់តែមានប្រសិទ្ធិភាព និងធានានូវគុណភាព និងភាពទាន់ពេលវេលា នៃការផ្តល់សេវារបបសន្តិ-សុខសង្គមជូនសមាជិក ប.ស.ស ។

**ឯកឧត្តម** ប្រតិភូរាជរដ្ឋាភិបាល បានថ្លែងបន្តទៀតថា៖ ប្រធាន អនុប្រធាន និងមន្ត្រី ប.ស.ស តាមបណ្តាសាខាទូទាំងរាជធានី ខេត្ត-ខណ្ឌ ទាំងអស់ ត្រូវតែអនុវត្តតួនាទីរបស់ខ្លួនឱ្យបានត្រឹមត្រូវ ដើម្បីឆ្លើយតបទៅនឹងគោលនយោបាយជាតិគាំពារសង្គមរបស់រាជរដ្ឋាភិបាល ប្រកបដោយប្រសិទ្ធិភាពខ្ពស់។ គួរបញ្ជាក់ផងដែរថា វគ្គបណ្តុះបណ្តាលខាងលើនេះ ប្រព្រឹត្តទៅមានរយៈពេល ៥ថ្ងៃ គឺចាប់ពីថ្ងៃទី១ ដល់ថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៩ ៕







# ពិធីសូត្រមន្តប្រោះព្រំលើករាសី សុំសិរីសួស្តី ជ័យមង្គលវិបុលសុខ ជូនដល់មន្ត្រីបុគ្គលិក នៃបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស)

តាមទំនៀមទំលាប់ប្រពៃណីព្រះពុទ្ធសាសនាជាតិខ្មែរ នារសៀលថ្ងៃសុក្រ ១កើត ខែចេត្រ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៩ ក្រោមអធិបតីភាព **ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**ឯកឧត្តម** ប្រតិភូបានឱ្យដឹងថា៖ ពិធីនេះធ្វើឡើងជារៀងរាល់ឆ្នាំដើម្បីប្រោះព្រំលើករាសី សុំសិរីសួស្តី ជ័យមង្គលវិបុលសុខជូនដល់ថ្នាក់ដឹកនាំ មន្ត្រីរាជការ ព្រមទាំងបុគ្គលិកផង និងអបអរសាទរពិធីបុណ្យចូលឆ្នាំប្រពៃណីជាតិខ្មែរ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ផង ស្ថិតនៅសាលប្រជុំធំនៃបេឡាជាតិរបបសន្តិសុខសង្គម ស្នាក់ការកណ្តាលរាជធានីភ្នំពេញ៕







# ប្រធាន អនុប្រធាន និងមន្ត្រីទទួលបន្ទុកសាខា ប.ស.ស ខេត្ត-ខណ្ឌ ទាំងអស់ ត្រូវតែបន្តពង្រឹងសមត្ថភាព និងអនុវត្តតួនាទីរបស់ខ្លួនឱ្យ កាន់តែប្រសើរជាងមុន

នេះជាលើក ទី២ ហើយ គ្រាន់តែប៉ុន្មានខែ នៃដើមឆ្នាំ ២០១៩ នេះ ប្រធាន អនុប្រធាន និងមន្ត្រី ប.ស.ស តាមបណ្ដាសាខាទូទាំងរាជធានី/ខេត្ត-ខណ្ឌ បានមកចូលរួមវគ្គបណ្ដុះ-បណ្ដាល ស្ដីពីបច្ចុប្បន្នភាពការងារជំនាញទាក់ទងនឹងរបប-សន្តិសុខសង្គម នៅសាលប្រជុំធំ នៃ ប.ស.ស ស្នាក់ការកណ្ដាល ក្នុងរាជធានីភ្នំពេញ។

**ឯកឧត្តម អ៊ឹក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកបេឡាជាតិរបបសន្តិសុខសង្គម នៃក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ បានអញ្ជើញជាអធិបតីភាព នៅក្នុងពិធីបិទវគ្គបណ្ដុះបណ្ដាល ស្ដីពីបច្ចុប្បន្នភាពការងារជំនាញទាក់ទងនឹងរបបសន្តិសុខសង្គម ដល់ប្រធាន អនុប្រធាន និងមន្ត្រី ប.ស.ស តាមបណ្ដាសាខាទូទាំងរាជធានី/ខេត្ត-ខណ្ឌ នៅថ្ងៃសុក្រ ១កើត ខែចេត្រ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៩នេះ បានថ្លែងថា៖





ឆ្លងកាត់វគ្គបណ្តុះបណ្តាលចំនួន ៤ថ្ងៃកន្លងមកនេះ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា ប្រធាន អនុប្រធាន និងលោក លោកស្រី មន្ត្រីទទួលបន្ទុកសាខា ប.ស.ស ខេត្ត-ខណ្ឌទាំងអស់ កាន់តែទទួលបានចំណេះដឹង ក៏ដូចជាបទពិសោធន៍ថ្មីៗយ៉ាងច្រើន ដើម្បីយកទៅដឹកនាំបំពេញកិច្ចការរបស់ខ្លួនឱ្យកាន់តែប្រសើរជាងមុនបើទោះបីកន្លងមកប្រសិទ្ធិភាពក្នុងការធានាបាននូវគុណភាព នៃការផ្តល់សេវារបបសន្តិសុខសង្គមជូនសមាជិក ប.ស.ស ទទួលបាននូវលទ្ធផលគួរឱ្យកត់សម្គាល់យ៉ាងណាក៏ដោយ។

**ឯកឧត្តម** ប្រតិភូរាជរដ្ឋាភិបាល ក៏បានលើកឡើងពីអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានថ្លែងឡើងកន្លងមកថា " មន្ត្រីទាំងអស់គឺធ្វើការបម្រើរាស្ត្រ មិនមែនជាចៅហ្វាយនាយរបស់រាស្ត្រនោះទេ និងត្រូវគោរព អនុវត្តន៍តួនាទីរបស់ខ្លួនឱ្យបានត្រឹមត្រូវស្របតាមអភិក្រមទាំង៥ ដែលប្រមុខរាជរដ្ឋាភិបាលបានដាក់ចេញឱ្យមន្ត្រីគ្រប់ជាន់ថ្នាក់គោរព និងអនុវត្តតាម " ។ ជាមួយគ្នានេះ ឯកឧត្តម ក៏បានផ្តាំផ្ញើឱ្យ ប្រធាន អនុប្រធាន និងលោក លោកស្រី មន្ត្រីទទួលបន្ទុកសាខា ប.ស.ស ខេត្ត-ខណ្ឌទាំងអស់ ជួយអំពាវនាវទៅដល់សមាជិក ប.ស.ស ទាំងអស់គប្បីផ្តល់ព័ត៌មានមកកាន់ ប.ស.ស តាមរយៈលេខ ១២៨៦ ឬឆាតមកកាន់ Facebook Page ផ្លូវការរបស់បេឡាជាតិរបបសន្តិសុខសង្គម ក្នុងករណីមានបញ្ហាក្នុងការទទួលសេវា ៕







# ប្រធានអង្គភាពធានារ៉ាប់រងសុខភាពជាតិ នៃសាធារណៈរដ្ឋកូរ៉េ ចុះអនុស្សរណៈយោគយល់មួយជាមួយប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកបេឡាជាតិរបបសន្តិសុខសង្គម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ




**ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកបេឡាជាតិរបបសន្តិសុខសង្គម នៅក្នុងពិធីចុះអនុស្សារណៈយោគយល់គ្នានេះបានថ្លែងថា៖ការចុះអនុស្សារណៈយោគយល់គ្នានាពេលនេះ ក្នុងគោលបំណងបង្កើតជំនាញទំនាក់ទំនងផ្នែកជំនាញបច្ចេកទេសផ្លាស់ប្តូរបទពិសោធន៍ និងចំណេះដឹងទាក់ទងទៅនឹងប្រព័ន្ធ ជំនាញផ្នែកគ្រប់គ្រងហិរញ្ញវត្ថុពីគ្នាទៅវិញទៅមក និងផ្តល់ឱកាសសិក្សារៀនសូត្រតាមរយៈការអនុវត្តជាក់ស្តែង។

**ឯកឧត្តម** ប្រតិភូថ្លែងបន្តថា ៖ ការចាប់ដៃគ្នាយ៉ាងស្អិតរមួតក្នុងការបង្កើតទំនាក់ទំនងនៃកិច្ចសហប្រតិបត្តិការបច្ចេកទេសទូលំទូលាយ ដើម្បីពង្រឹងរបបធានារ៉ាប់រងសុខភាពរវាងប្រទេសទាំងពីរ នាពេលនេះ មិនត្រឹមតែបង្ហាញអំពីការទំនាក់ទំនងសាមគ្គីភាពរវាងអង្គភាពទាំងពីរនោះទេ ពោលគឺនៅបានបង្ហាញអំពីការទំនាក់ទំនងដ៏ល្អរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណៈរដ្ឋកូរ៉េ ក្នុងនាមជាអ្នកជិតខាង និងក្នុងនាមជាបង ជាប្អូនក្នុងតំបន់អាស៊ីនេះផងដែរ។





**ឯកឧត្តម** ប្រតិភូរាជរដ្ឋាភិបាលសង្ឃឹម និងជឿជាក់យ៉ាងមុតមាំថា កិច្ចសហការរវាងអង្គភាពទាំងពីរ ពិតជាសញ្ញាណមួយនៃការអភិវឌ្ឍជំនាញបច្ចេកទេស បង្កើនកម្មវិធី និងបទពិសោធន៍ថ្មីៗ ក្នុងការអភិវឌ្ឍរបបធានារ៉ាប់រងសុខភាពឱ្យកាន់តែប្រសើរឡើងស្របតាមបច្ចុប្បន្នកាល និងអនាគតកាល។

**ឯកឧត្តម** បានបញ្ជាក់បន្តថា ៖ ព្រះរាជាណាចក្រកម្ពុជាធ្លាប់បានធ្លាក់ចូលក្នុងស្ថានភាពដ៏លំបាកបំផុតក្នុងសម័យកាលកម្ពុជាប្រជាធិបតេយ្យ ដែលពេលនោះមេដឹកនាំផ្តាច់ការបានបំផ្លាញធនធានមនុស្ស និងហេដ្ឋារចនាសម្ព័ន្ធស្ទើរតែទាំងស្រុង។ ក្រោយពីទទួលបាននូវសុខសន្តិភាពទូទាំងប្រទេស ក្រោមការជួយរំដោះនិងការដឹកនាំប្រទេសពីសំណាក់ប្រមុខរាជរដ្ឋាភិបាលបច្ចុប្បន្ន ធ្វើឱ្យកម្ពុជាប្រែមុខមាត់ថ្មី និងបានអភិវឌ្ឍន៍ខ្លួនទៅមុខយ៉ាងស្វាហាប់ប្រកបដោយថាមពល និងសម្រេចបានជោគជ័យលើគ្រប់វិស័យ ក្នុងនោះដែរវិស័យមួយដែលពុំធ្លាប់មានក្នុងសង្គមកម្ពុជាកន្លងមក គឺវិស័យសន្តិសុខសង្គម មានបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) ដែលជាគ្រឹះស្ថានសាធារណៈរដ្ឋបាលទទួលបន្ទុកអនុវត្ត ត្រូវបានបង្កើតឡើងនៅឆ្នាំ២០០៧។ ប.ស.ស បច្ចុប្បន្នមានការិយាល័យតាមបណ្តាខេត្តចំនួន ២៤ និងខណ្ឌចំនួន ៤ មានមន្រ្តី និងបុគ្គលិកសរុប ១ ៤១៤នាក់ និងបានដាក់ឱ្យដំណើការរបបសន្តិសុខសង្គមសម្រាប់វិស័យឯកជន និងវិស័យសាធារណៈ។

**ឯកឧត្តម** ប្រតិភូបានថ្លែងបញ្ជាក់បន្ថែមទៀតថា៖ សម្រាប់វិស័យឯកជន ផ្នែកហានិភ័យការងារចាប់ផ្តើមអនុវត្តនៅឆ្នាំ២០០៨ ហើយមកដល់បច្ចុប្បន្ន ប.ស.ស បានចុះបញ្ជីសហគ្រាសចំនួន ១២ ៦៦៣ និងមានកម្មករនិយោជិតចំនួន ១ ៦៣៧ ៨៧៦នាក់ និងបានផ្តល់តាវកាលិកចំនួន ២២០ ៨៨៩ដង-នាក់។ ដោយឡែកផ្នែកថែទាំសុខភាពត្រូវបានដាក់ឱ្យដំណើរការនៅក្នុងខែកញ្ញា ឆ្នាំ២០១៦ បានចុះបញ្ជីសហគ្រាសចំនួន ១០ ៤១៨ មានកម្មករចំនួន ២ ០០៧ ២៥២នាក់ មានកម្មករនិយោជិតទៅទទួលសេវាចំនួន ២ ២៥១ ៨០០ ដង-នាក់ និងគ្រោងរៀបចំដាក់ឱ្យដំណើរការផ្នែកប្រាក់សោធននៅឆ្នាំ២០១៩ ។ ដោយមានទំនុកចិត្ត និងភាពជឿជាក់មកលើ ប.ស.ស រាជរដ្ឋាភិបាលកម្ពុជា ក៏បានប្រគល់ភារកិច្ចបន្ថែមដល់ ប.ស.ស ក្នុងនាមជាប្រតិបត្តិករអនុវត្តរបបសន្តិសុខសង្គមសម្រាប់វិស័យសាធារណៈ ផ្នែកថែទាំសុខភាព សម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន ដែលបច្ចុប្បន្នមានមន្ត្រីរាជការ ៣១៧ ៥០៩នាក់






ត្រូវបានចុះបញ្ជិកា (មន្ត្រីសាធារណៈចំនួន ២០៧ ៥១៧នាក់ អតីតមន្ត្រីរាជការចំនួន ៥៥ ២២២នាក់ អតីតយុទ្ធជនចំនួន ៥៥ ២៧៧នាក់) និងមានមន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន ទៅទទួលសេវាថែទាំសុខភាពបានចំនួន ៣១ ៨៦៤ដង-នាក់ និងគ្រោងអនុវត្តផ្នែកហានិភ័យសម្រាប់មន្ត្រីសាធារណៈនាពេលខាងមុខដ៏ខ្លីនេះផងដែរ។ ដោយឡែកការអនុវត្តរបបថែទាំសុខភាព តាមប្រព័ន្ធមូលនិធិសមធម៌សុខាភិបាល ដោយអនុលោមតាមប្រកាសអន្តរក្រសួងរវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងសុខាភិបាល លេខ៤៩៧ ស.ហ.វ-ប្រកចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៨ ស្តីពីតម្លៃកញ្ចប់សេវាព្យាបាលរបស់មូលនិធិសមធម៌សុខាភិបាល ប្រាក់ឧបត្ថម្ភបន្ថែមសម្រាប់កម្មករនិយោជិតជាស្ត្រីនៅពេលសម្រាលកូន និងនីតិវិធីអនុវត្តចំណាយព្រមទាំងបានចុះបញ្ជីកម្មករនិយោជិតក្រៅប្រព័ន្ធបានចំនួន ២៣ ០៤៦សហគ្រាស និងកម្មករ ១២៣ ៧៩១នាក់។

សូមបញ្ជាក់ថា ការចុះអនុស្សារណៈយោគយល់គ្នានេះត្រូវបានធ្វើឡើងក្នុងខណៈពេល ដែលប្រតិភូបេឡាជាតិរបបសន្តិសុខសង្គម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលដឹកនាំដោយ **ឯកឧត្តម អ៊ិត សមហិនៀ** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកបេឡាជាតិរបបសន្តិសុខសង្គមចុះទៅបំពេញការងារនៅសាធារណៈរដ្ឋកូរ៉េចាប់ពីថ្ងៃទី ១២ ដល់ ១៥ មេសា ឆ្នាំ២០១៩៕








# បច្ចុប្បន្នវិស័យសេដ្ឋកិច្ចកម្ពុជាមានការរីកចម្រើន ក្នុងនោះក៏មានវិស័យកាត់ដេរ និងផលិតស្បែកជើងផងដែរ

**ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានថ្លែងឡើងក្នុងន័យខាងលើនេះ ត្រូវបានប្រព្រឹត្តទៅ នៅក្នុងពិធីប្រជុំបូកសរុបលទ្ធផលការងារសម្រេចបានឆ្នាំ២០១៨ និងទិសដៅបន្តឆ្នាំ២០១៩ របស់ក្រុមការងារទប់ស្កាត់ករណីសន្លប់ និងបង្ការគ្រោះថ្នាក់ការងាររបស់កម្មករនិយោជិត (ទ.ស.ប.ក) និងក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត (ស.ផ.ក) នៅក្នុងសាលប្រជុំធំរបស់ ប.ស.ស នៅថ្ងៃអង្គារ ១១រោច ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៩ ។

**ឯកឧត្តម** ប្រតិភូរាជរដ្ឋាភិបាល បានថ្លែងបន្តថា៖ ក្រោមការដឹកនាំដ៏ឈ្លាសវៃប្រកបដោយគតិបណ្ឌិតពីសំណាក់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ប្រទេសជាតិមានសុខសន្តិភាព បច្ចុប្បន្នវិនិយោគិនទាំងនៅក្រៅស្រុក និងនៅក្នុងស្រុកបានដាក់ទុនវិនិយោគយ៉ាងច្រើននៅកម្ពុជា ដែលបានបង្កើតការងារជូនដល់ប្រជាពលរដ្ឋទូទៅនៅក្នុងប្រទេសបានជាច្រើនផងដែរក្នុងមួយឆ្នាំៗ ។ មកដល់ពេលនេះ វិស័យសេដ្ឋកិច្ចកម្ពុជាមានការរីកចម្រើនលើគ្រប់ផ្នែក ក្នុងនោះក៏មានវិស័យកាត់ដេរនិងផលិតស្បែកជើងផងដែរ ដែលនាំទៅដល់ការលើកកម្ពស់សេដ្ឋកិច្ចគ្រួសារដោយផ្ទាល់សម្រាប់កម្មករនិយោជិកនៅកម្ពុជា ។





**ឯកឧត្តម** ប្រតិភូ បានថ្លែងបន្តទៀតថា៖ ស្របទៅនឹងការរីកចម្រើននេះ រាជរដ្ឋាភិបាលក៏បានគិតគូរទៅដល់សុខភាពរបស់កម្មករនិយោជិត ក្នុងពេលបំពេញការងារដែលជាភាពប្រឈម នៅចំពោះមុខថែមទៀតផង ក្នុងនោះដូចជាករណីគ្រោះថ្នាក់ការងារ ករណីសន្លប់ និងករណីគ្រោះថ្នាក់ចរាចរណ៍ជាដើម ។ ស្ថិតនៅក្នុងស្ថានការ ដែលជាកង្វល់នេះ រាជរដ្ឋាភិបាលដែលមានសាមីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជាសេនាធិការ បានបង្កើតក្រុមការងារទប់ស្កាត់ករណីសន្លប់ និងបង្ការគ្រោះថ្នាក់ការងាររបស់កម្មករនិយោជិត (ទ.ស.ប.ក) និងក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោក សម្រាប់ទប់ស្កាត់នូវរាល់ករណីគ្រោះថ្នាក់ទាំងនេះ។ ក្នុងនោះក៏មាន ក្រសួងមហាផ្ទៃ ក្រសួងសុខាភិបាល ក្រសួងសាធារណៈការ និងដឹកជញ្ជូន សាលារាជធានីភ្នំពេញ កាកបាទក្រហមកម្ពុជា សហភាពសហព័ន្ធយុវជនកម្ពុជា សមាគមរោងចក្រកាត់ដេរនៅកម្ពុជា សហជីពតំណាងកម្មករនិយោជិត អង្គការជនពិការអន្តរជាតិ និងអង្គការមូលនិធិបង្ការរបួសអាស៊ី។

បើយោងតាមរបាយការណ៍ប្រចាំឆ្នាំ ២០១៨ ដែលថ្លែងឡើង ដោយ **ឯកឧត្តម ហេង សុផាន់ណារិទ្ធ** ប្រធានការិយាល័យគោលនយោបាយនៃបេឡាជាតិរបបសន្តិសុខសង្គម បានឲ្យដឹងថា៖ កន្លងមកក្រុមការងារ ទ.ស.ប.ក បានចុះអង្កេត និងសិក្សាស្រាវជ្រាវករណីកម្មករនិយោជិតសន្លប់ ដើម្បីស្វែងរកមូលហេតុ និងចាត់វិធានការកែលម្អលើរោងចក្រ ដែលមានកម្មករនិយោជិតសន្លប់មានចំនួន ១៧រោងចក្រ និងកម្មករនិយោជិតសន្លប់ចំនួន ២ ១០៩នាក់។



បើប្រៀបធៀបនឹងឆ្នាំ២០១៧ គឺមានការថយចុះចំនួន ៥រោងចក្រ ស្មើនឹង ២៣% និងកម្មករនិយោជិតសន្លប់កើនឡើងចំនួន ៥០៦នាក់ ស្មើនឹង ៣២% ភាគច្រើនកម្មករនិយោជិតដែលរងគ្រោះ គឺបានផ្តើមចេញពីកម្មករនិយោជិតសន្លប់តែពីម្នាក់ ឬពីរនាក់តែប៉ុណ្ណោះ ប៉ុន្តែគឺបានឆ្លងនូវជំងឺស្នេហ៍ហ្វូង ។

មូលហេតុចម្បងៗដែលបណ្តាលឱ្យមានករណីសន្លប់កើតមានឡើងរួមមានដូចជាបញ្ហាចិត្តសាស្ត្រសង្គមមានចំនួន ៣៧% បញ្ហាគីមីមានចំនួន ២០%បញ្ហារូបសាស្ត្រមានចំនួន ១៥%បញ្ហាការងារបន្ថែមម៉ោងមានចំនួន១៣%បញ្ហាជីវសាស្ត្រមានចំនួន ១១%បញ្ហាវិទ្យាសាស្ត្ររៀបចំការងារមានចំនួន ២% និងបញ្ហាមេកានិចមានចំនួន ២%។ ទាក់ទងទៅនឹងបញ្ហានេះ **ឯកឧត្តម** ប្រតិភូ បានជំរុញឱ្យក្រុមការងារ ទ.ស.ប.ក បន្តបង្កើនការផ្សព្វផ្សាយអប់រំបន្ថែមទៀត ដល់កម្មករនិយោជិតនៅតាមបណ្តាសហគ្រាស គ្រឹះស្ថាននានា ឱ្យមានការយល់ដឹងខ្ពស់បន្ថែមទៀត ពាក់ព ន្ធ័និង ស្ថានភាពប្រឈមនេះ ដើម្បីកម្មករនិយោជិតទទួលបាននូវសុខភាពដ៏ល្អប្រសើរគ្រប់ពេលវេលា ក្នុងការជម្រុញដល់ការលើកកម្ពស់ជីវភាពរស់នៅដោយផ្ទាល់ ក៏ដូចជារួមចំណែកលើកកម្ពស់វិស័យសេដ្ឋកិច្ចកម្ពុជាឱ្យមានការរីកចម្រើនឥតឈប់ឈរ៕









# គ្រោះថ្នាក់ចរាចរណ៍នៅតែជាកង្វល់ដ៏ធ្ងន់ធ្ងរមួយរបស់រាជរដ្ឋាភិបាល

**ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកបេឡាជាតិរបបសន្តិសុខសង្គម និងជាប្រធានក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត (ស.ផ.ក) និងជាសមាជិកគណៈកម្មការសុវត្ថិភាពចរាចរណ៍ផ្លូវគោកនៅក្នុងសិក្ខាសាលាស្តីពីការពិគ្រោះយោបល់លើសេចក្តីពីព្រាងផែនការសកម្មភាពសុវត្ថិភាពចរាចរណ៍ផ្លូវគោកចំពោះកម្មករ ដែលបានធ្វើឡើងនៅសណ្ឋាគារ ហ៊ី ម៉ាវ៉ារី បានថ្លែងថា ៖ គ្រោះថ្នាក់ចរាចរណ៍ គឺជាឃាតករលាក់មុខ ដែលធ្វើឱ្យមនុស្សស្លាប់ របួស និងពិការជារៀងរាល់ថ្ងៃ។ បញ្ហាប្រឈមដ៏ធ្ងន់ធ្ងរនេះ មិនអាចឱ្យក្រសួង ស្ថាប័ន ឬផ្នែកណាមួយធ្វើការទប់ស្កាត់ កាត់បន្ថយ ឬលុបបំបាត់តែឯងបានឡើយ ប៉ុន្តែយើងអាចសហការគ្នាទប់ស្កាត់ និងកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ឱ្យស្ថិតនៅកម្រិតទាប។ ដើម្បីដោះស្រាយស្ថានភាពនេះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានបង្កើតក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត (ស.ផ.ក.) នៃបេឡាជាតិរបបសន្តិសុខសង្គម ដែលមានសមាសភាពជាក្រុមការងារអន្តរក្រសួង ក្នុងនោះមានដូចជា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងមហាផ្ទៃ ក្រសួងសុខាភិបាល ក្រសួងសាធារណការ និងដឹកជញ្ជូន សាលារាជធានីភ្នំពេញ កាកបាទក្រហមកម្ពុជា សហភាពសហព័ន្ធយុវជនកម្ពុជា សមាគមរោងចក្រកាត់ដេរនៅកម្ពុជា សហជីពតំណាងកម្មករនិយោជិត អង្គការជនពិការអន្តរជាតិ និងអង្គការមូលនិធិបង្ការរបួសអាស៊ី ដែលមានតួនាទីសំខាន់ក្នុងការចូលរួមលើកកម្ពស់សុវត្ថិភាពចរាចរណ៍ផ្លូវគោកដល់កម្មករនិយោជិត។











នៅក្នុងឆ្នាំ២០១៨ កន្លងទៅនេះ បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) បានធ្វើការចុះផ្សព្វផ្សាយអប់រំដល់កម្មករនិយោជិតបានចំនួន ៥៥៤លើក នឹងមានអ្នកចូលរួមចំនួន ១០៧ ៦២៨នាក់ នឹងបានចុះផ្សព្វផ្សាយអប់រំដល់អ្នកបើកបរយានយន្តដឹកកម្មករនិយោជិតបានចំនួន ២៦៤លើកនឹងមានអ្នកចូលរួមសរុបចំនួន ៤២ ១២៦នាក់ ។ បើទោះជាយ៉ាងនេះក្ដី នៅក្នុងឆ្នាំ២០១៨ កន្លងទៅ ករណីគ្រោះថ្នាក់ចរាចរណ៍បានកើតឡើងលើកម្មករនិយោជិតមានចំនួន ១ ៧១០លើក គ្រោះថ្នាក់ដោយរថយន្តមានចំនួន ២៧លើក (ក្នុងនោះ១៨លើកជារថយន្តដឹកកម្មករនិយោជិតបម្រើការងារក្នុងវិស័យកាត់ដេរសម្លៀកបំពាក់ និងផលិតស្បែកជើង) គ្រោះថ្នាក់ដោយម៉ូតូចំនួន ១ ៥៦៥លើក រ៉ឺម៉កចំនួន ១២លើក កង់ចំនួន ១៩លើក អ្នកថ្មើរជើងចំនួន ៨៦លើក នឹងរថភ្លើងចំនួន ១លើកដែលមានជនរងគ្រោះសរុបចំនួន ១ ៨៦៣នាក់ បណ្ដាលឱ្យស្លាប់ចំនួន ៤២នាក់ របួសធ្ងន់ចំនួន ៣៣២នាក់ នឹងរបួសស្រាលចំនួន ១ ៤៨៩នាក់។ **ឯកឧត្តម** ប្រតិភូរំពឹងថា៖ ឆ្លងកាត់សិក្ខាសាលារយៈពេលពេញមួយព្រឹកនេះ នឹងទទួលបានលទ្ធផលល្អប្រសើរប្រកបដោយផ្លែផ្កា ក្នុងការចូលរួមអនុវត្តផែនការសកម្មភាព "**សុវត្ថិភាពចរាចរណ៍ផ្លូវគោក ចំពោះកម្មករនិយោជិត**" ឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ បេឡាជាតិរបបសន្តិសុខសង្គម និងអគ្គស្នងការដ្ឋាននគរបាលជាតិ ត្រូវបង្កើននូវកិច្ចសហការ ក្នុងការចូលរួមផ្សព្វផ្សាយអប់រំច្បាប់ស្ដីពីចរាចរណ៍ផ្លូវគោក សុវត្ថិភាពក្នុងការធ្វើដំណើរគ្រប់រូបភាពក្នុងន័យចូលរួមកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោក ដែលអាចធ្លាក់មកលើកម្មករនិយោជិតឱ្យស្ថិតនៅកម្រិតទាបបំផុត។

សូមបញ្ជាក់ថា៖ សិក្ខាសាលានេះ ប្រព្រឹត្តទៅនៅព្រឹកថ្ងៃសុក្រ ១២កើត ខែជេស្ឋ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៩ ដោយមានវត្តមាន **ឯកឧត្តម នាយឧត្តមសេនីយ៍ ហ៊ីម យ៉ាន** អគ្គស្នងការរងនគរបាលជាតិ និងជាអនុប្រធានអចិន្ត្រៃយ៍អនុគណៈកម្មាការទី២ ដោយមានការចូលរួមពីតំណាងក្រសួង ស្ថាប័ន មន្ទីរសាធារណការដឹកជញ្ជូន ស្នងការដ្ឋាននគរបាល សមាគមរោងចក្រកាត់ដេរនៅកម្ពុជា (GMAC) និងអង្គការសង្គមស៊ីវិលពាក់ព័ន្ធនានាសរុបប្រមាជាង ១០០នាក់ នៅសណ្ឋាគារហ៊ីម៉ាវ៉ារីរាជធានីភ្នំពេញ ។



# ក្រុមការងារ ប.ស.ស សហការជាមួយរដ្ឋបាលខេត្តប៉ៃលិន រៀបចំពិធីប្រជុំផ្សព្វផ្សាយអំពីគោលនយោបាយនៃការអនុវត្តរបបសន្តិសុខសង្គម




នៅថ្ងៃចន្ទ ៥រោច ខែផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៩ ក្រុមការងារបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) នៃក្រសួងការងារ និងបណ្តុះ-បណ្តាលវិជ្ជាជីវៈ បានសហការជាមួយរដ្ឋបាលខេត្តប៉ៃលិន រៀបចំពិធីប្រជុំផ្សព្វផ្សាយអំពីគោលនយោបាយនៃការអនុវត្តរបបសន្តិសុខសង្គម ដល់និយោជក ម្ចាស់សហគ្រាស គ្រឹះស្ថាន។

កម្មវិធីនេះប្រព្រឹត្តទៅ ក្រោមអធិបតីភាព **ឯកឧត្តម ចេង ញ៉ាន់** អភិបាលរង និងជាតំណាងឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្តប៉ៃលិន **ឯកឧត្តម ម៉េង ហុង** នាយករងតំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម អ៊ឹក សមវិទ្យា** ប្រតិភូរាជរដ្ឋា-ភិបាលទទួលបន្ទុកជានាយក ប.ស.ស ព្រមទាំងមានការអញ្ជើញចូលរួមពី មន្ទីរ អង្គភាព ចំណុះរដ្ឋបាលខេត្តប៉ៃលិន មន្ត្រី និងបុគ្គលិក សាខា ប.ស.ស ខេត្ត មូលដ្ឋានសុខាភិបាលចុះកិច្ចព្រមព្រៀង និយោជក ម្ចាស់ សហគ្រាស គ្រឹះស្ថាន និងតំណាងជនរងគ្រោះដែលកំពុងទទួលបានតាវកាលិកបាត់បង់សមត្ថភាពអចិន្ត្រៃយ៍ និងឧត្តរជីវី (អ្នកនៅក្នុងបន្ទុក) ចំនួន១៤៨នាក់ នៅសាលាខេត្តប៉ៃលិន។

ឆ្លៀតក្នុងឱកាសនោះផងដែរ **ឯកឧត្តម** អភិបាលរងខេត្ត បានសម្តែងក្តីសោមនស្សរីករាយ និងស្វាគមន៍ចំពោះវត្តមានក្រុមការងារ នៃបេឡាជាតិរបបសន្តិសុខសង្គម ដែលបានចុះផ្សព្វផ្សាយពីអត្ថប្រយោជន៍ ប.ស.ស និងបានថ្លែងអំណរគុណចំពោះក្រុមការងារ ប.ស.ស និងអ្នកពាក់ព័ន្ធ ដែលបានរៀបចំ និងចូលរួមកម្មវិធីនេះ ព្រមទាំងផ្តាំផ្ញើឱ្យមន្ត្រី និងបុគ្គលិក សាខា ប.ស.ស ខេត្ត មូលដ្ឋានសុខាភិបាលចុះកិច្ចព្រមព្រៀង និយោជកម្ចាស់ សហគ្រាស គ្រឹះស្ថាន ឬតំណាង ជនរងគ្រោះដែលកំពុងទទួលបានតាវកាលិកបាត់បង់សមត្ថភាពអចិន្ត្រៃយ៍ និងឧត្តរជីវី (អ្នកនៅក្នុងបន្ទុក) ឱ្យយកចិត្តទុកដាក់ស្តាប់។




**ឯកឧត្តម ម៉េង ហុង** នាយករង ប.ស.ស បានថ្លែងថា គោលបំណងកម្មវិធីនេះ ដើម្បីផ្សព្វផ្សាយអំពីគោលនយោបាយនៃការអនុវត្តរបបសន្តិសុខសង្គម បញ្ហាប្រឈម ជាពិសេសធ្វើការពង្រឹងសេវានៃការផ្តល់តាវកាលិកជូនកម្មករនិយោជិត និងពន្យល់បញ្ជាក់ឱ្យកាន់តែច្បាស់ពីរបបសន្តិសុខសង្គមៈ

១. ផ្នែកហានិភ័យការងារ គឺគ្រោះថ្នាក់ទាំងឡាយណាដែលកើតឡើងក្នុងកំឡុងពេលបំពេញការងារ ពេលធ្វើដំណើរពីផ្ទះទៅកន្លែងធ្វើការ និងពីកន្លែងធ្វើការត្រលប់ទៅផ្ទះវិញ ដោយមិនមានការវាងចូលកន្លែងណាមួយជាប្រយោជន៍ផ្ទាល់ខ្លួននិងជំងឺវិជ្ជាជីវៈ។

២. ផ្នែកថែទាំសុខភាព ផ្នែកថែទាំសុខភាព សំដៅដល់ការធានារ៉ាប់រងសុខភាពសង្គមដូចជាៈ

-ការផ្តល់សេវាព្យាបាល និងថែទាំវេជ្ជសាស្ត្រ

-ការផ្តល់សេវាបង្ការសុខភាព

-ការផ្តល់ប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់រយៈពេលនៃការអាក់ខានការងារដោយការព្យាបាលជំងឺឬគ្រោះថ្នាក់ផ្សេងៗក្រៅពីហានិភ័យការងារ និងការសម្រាកមាតុភាព។

៣. ផ្នែកប្រាក់សោធន ចាប់ផ្តើមដាក់ឱ្យអនុវត្តន៍នៅឆ្នាំ ២០១៩៕










# កិច្ចប្រជុំស្តីពីការបង្ហាញលទ្ធផលបឋម និងពិគ្រោះយោបល់លើសេចក្តីព្រាង ផែនការយុទ្ធសាស្ត្រ (២០២០-២០២៥) របស់ទីភ្នាក់ងារបញ្ជាក់ចំណាយសេវាសុខាភិបាល

ដោយការអញ្ជើញពីទីភ្នាក់ងារបញ្ជាក់ចំណាយសេវាសុខាភិបាល (ទ.ប.ច.ស) នៃក្រសួងសុខាភិបាល **ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចាត់ **ឯកឧត្តម ហេង សុផាន់ណារិទ្ធ** ប្រធានការិយាល័យគោលនយោបាយនៃ ប.ស.ស ឱ្យចូលរួមកិច្ចប្រជុំបង្ហាញលទ្ធផលបឋម និងពិគ្រោះយោបល់លើសេចក្តីព្រាងផែនការយុទ្ធសាស្ត្រ (២០២០-២០២៥) របស់ទីភ្នាក់ងារបញ្ជាក់ចំណាយសេវាសុខាភិបាល ដែលប្រព្រឹត្តទៅនៅថ្ងៃពុធ ៨កើត ខែផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៩ ស្ថិតនៅសណ្ឋាគារភ្នំពេញ។






គោលបំណងនៃកិច្ចប្រជុំពិភាក្សាខាងលើនេះ ត្រូវបានរៀបចំឡើងដើម្បីការអភិវឌ្ឍផែនការយុទ្ធសាស្ត្រសម្រាប់ទីភ្នាក់ងារបញ្ជាក់ចំណាយសុខាភិបាល សម្រាប់ឆ្នាំ ២០២០-២០២៥ ដែលស្របទៅនឹងក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ឆ្នាំ ២០១៦-២០២៥ ផែនការយុទ្ធសាស្ត្រសុខាភិបាលជំហានទី៣ អនុក្រឹត្យស្តីពីការបង្កើតទីភ្នាក់ងារបញ្ជាក់ចំណាយសេវាសុខាភិបាល គម្រោងលើកកម្ពស់គុណភាព និងសមធម៌សុខាភិបាលនៅកម្ពុជា ព្រមទាំងបទប្បញ្ញត្តិផ្សេងៗទៀត។





កិច្ចប្រជុំពិភាក្សាខាងលើនេះ មានការចូលរួមពីតំណាងទីភ្នាក់ងារបញ្ជាក់ចំណាយសេវាសុខាភិបាល(Payment Certification Agency) តំណាងបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តំណាងក្រសួងមហាផ្ទៃ តំណាងក្រសួងផែនការ តំណាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនិតិសម្បទា តំណាងអង្គការ GFA ព្រមទាំងមានការចូលរួមពីតំណាងអង្គភាពពាក់ព័ន្ធនានា សរុបប្រមណ ៣០នាក់ ៕









# មន្ត្រីជំនាញ នៃបេឡាជាតិរបបសន្តិសុខសង្គម ចូលរួមសន្និសីទស្តីពី “ការទូទាត់សំណង និងការផ្តល់សេវាហិរញ្ញប្បទានលើការថែទាំសុខភាពបឋម” លើកទី១ របស់ខ្លួននៅប្រទេសម៉ាឡេស៊ី

តបតាមការអញ្ជើញពីអង្គការបណ្តាញសិក្សារួមគ្នា (Joint Learning Network) **ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជានាយកបេឡាជាតិរបបសន្តិសុខសង្គម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៅថ្ងៃអង្គារ ១២កើត ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី១៦ ខែមេសា ឆ្នាំ២០១៩ បានចាត់ **ឯកឧត្តម ហេង សុផាន់ណារិទ្ធ** ប្រធានការិយាល័យគោលនយោបាយ និងលោក អ៊ុក សំអូន មន្ត្រីជំនាញ នៃបេឡាជាតិរបបសន្តិសុខសង្គម ទៅចូលរួមក្នុងសន្និសីទស្តីពី "ការទូទាត់សំណង និងការផ្តល់សេវាហិរញ្ញប្បទានលើការថែទាំសុខភាពបឋម" ដែលប្រព្រឹត្តទៅចំនួន ៣ថ្ងៃ គឺចាប់ពីថ្ងៃទី១៦ ដល់ថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៩ ស្ថិតនៅទីក្រុងកូឡាឡាំពួ នៃប្រទេសម៉ាឡេស៊ី ក្រោមជំនួយឧបត្ថម្ភរបស់បណ្តាញសិក្សារួមគ្នា (Joint Learning Network) និងសមាសភាពអ្នកចូលរួមសរុបប្រមាណជាង ៥០នាក់ មកពី ១៤ប្រទេស ក្នុងពិភពលោក។ សន្និសីទចំនួន ៣ថ្ងៃនេះ គឺផ្តោតសំខាន់ទៅលើការសិក្សា និងការផ្លាស់ប្តូរបទពិសោធន៍ ស្តីពីការធ្វើសុខដុមនីយកម្ម និងការផ្តល់អនុភាព នៃយន្តការទូទាត់សំណងផ្នែកថែទាំសុខភាព ដើម្បីគាំទ្រដល់ការគ្របដណ្តប់សេវាសុខភាពជាសកល (Universal Health Coverage) ទៅលើការទូទាត់សំណង និងហិរញ្ញប្បទានបឋមផ្នែកថែទាំសុខភាព។ គួរបញ្ជាក់ផងដែរថា ដោយមានជំនួយឧបត្ថម្ភ និងកិច្ចសហការដ៏ល្អពីអង្គការ GIZ ប្រទេសកម្ពុជាបានក្លាយទៅជាសមាជិករបស់បណ្តាញសិក្សារួមគ្នា (JLN) កាលពីខែមីនា ឆ្នាំ២០១៩ ដែលមានសមាសភាពចូលរួមចំនួន ៦រូប ក្នុងនោះ មកពីអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុចំនួន ២រូប មកពីទីភ្នាក់ងារជាតិបញ្ជាក់ចំណាយសេវាសុខាភិបាល (PCA) នៃក្រសួងសុខាភិបាលចំនួន ២រូប និងមកពីបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈចំនួន ២រូប មកដល់បច្ចុប្បន្ននេះ បណ្តាញសិក្សារួមគ្នា (JLN) មានសមាជិកសរុបចំនួន ៣៤ប្រទេស ៕








# កិច្ចប្រជុំស្តីពី “ការយល់ដឹងពីប្រព័ន្ធគាំពារសង្គម សម្រាប់កម្មករវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ”

នៅថ្ងៃសៅរ៍ ៨រោច ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៩ បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចាត់ **ឯកឧត្តម ហេង សុផាន់ណារិទ្ធ** ប្រធានការិយាល័យគោលនយោបាយ ចូលជាវាគ្មិន ក្នុងកិច្ចប្រជុំរបស់គណៈកម្មការប្រតិបត្តិហូមណេត Southeast Asia ដោយផ្តោតសំខាន់លើ "ការយល់ដឹងពីប្រព័ន្ធគាំពារសង្គមសម្រាប់កម្មករវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ" ដែលប្រព្រឹត្តទៅចាប់ពីថ្ងៃទី២៧ ដល់ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៩ នៅសាលប្រជុំក្នុងសណ្ឋាគារ Angkor Holiday ដែលសមាសភាពអ្នកចូលរួមមកពីចំនួន៦ ប្រទេសដូចជា ប្រទេសកម្ពុជា ឡាវ ម៉ាឡេស៊ី ហ្វីលីពីន ឥណ្ឌូនេស៊ី វៀតណាម និងសមាគមរបស់ Homenet មកពីបណ្តារាជធានីខេត្តក្នុងព្រះរាជាណាចក្រកម្ពុជា សរុបប្រមាណជាង៥០នាក់។

កិច្ចប្រជុំនេះមានគោលបំណងចំបងដូចជា៖

- ពង្រីក និងពង្រឹងរចនាសម្ព័ន្ធ និងបច្ចុប្បន្នភាពរបស់អង្គការ Homenet
- ការអភិវឌ្ឍ និងការរៀបចំយុទ្ធសាស្ត្ររបស់សមាជិកភាពទាំងប្រទេសដែលជាសមាជិក និងតំបន់
- ការរៀបចំផែនការយុទ្ធសាស្ត្រ សម្រាប់បញ្ជៀតចូលប្រព័ន្ធគាំពារសង្គមដើម្បីសម្រេចបាន ការគ្របដណ្តប់សុខភាពជាសាកលទាំងប្រទេសដែលជាសមាជិកគ្រប់តំបន់ និងគ្រប់កម្រិត ជាពិសេសការរៀបចំផែនការសម្រាប់វេទិកាមនុស្សក្នុងតំបន់អាស៊ាន (APF) និង ការពិភាក្សាពីគោលការណ៍ និងការបង្កើតបណ្តាញសមាគម Homenet អន្តរជាតិ។

នៅក្នុងកិច្ចពិភាក្សានោះ ឯកឧត្តម ក៏បានលើកឡើងថា ក្រុមការងាររបស់បេឡាជាតិរបបសន្តិសុខសង្គម(ប.ស.ស) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បាននឹងកំពុងរៀបចំសេចក្តីព្រាងច្បាប់ស្តីពីសន្តិសុខសង្គម ហើយនាពេលថ្មីៗ បានការឯកភាពពីសមាជិកក្រុមប្រឹក្សាជាតិគាំពារសង្គម ហើយគ្រោងនឹងដាក់ប្រជុំពិនិត្យសម្រេចម្តងទៀតនាខែមិថុនា ហើយថ្មីៗនេះក្រុមការងារនៃ ប.ស.ស បានសហការជាមួយអង្គការ GRET and ILO ក៏ដូចជាសមាគមមួយចំនួន ដើម្បីសិក្សាការគ្របដណ្តប់លើកម្មករវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធផ្សេងទៀត ដែលមិនទាន់មានការគាំពារសង្គម ដូចជាអ្នករត់តុគុ ម៉ូតូឌុប ហើយជាពិសេសនោះគឺកម្មករវិស័យសំណង់ផងដែរ៕






# មន្ត្រីជំនាញនៃ ប.ស.ស ចំនួន៤រូប ចូលរួមកិច្ចប្រជុំផ្លាស់ប្តូរបទពិសោធន៍ ស្តីពីការផ្តល់សេវាស្តារនីតិសម្បទា របបសន្តិសុខសង្គមនៅប្រទេសវៀតណាម

នៅក្នុងទំនាក់ទំនងកិច្ចសហប្រតិបត្តិការដ៏ល្អមួយ រវាងប្រទេសជិតខាងភូមិផងរបងជាមួយថ្មីៗ **ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយក បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស.) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចាត់មន្ត្រីជំនាញនៃការិយាល័យស្តារនីតិសម្បទាចំនួន៤រូប ទៅបំពេញទស្សនកិច្ចសិក្សា ស្តីពីការផ្តល់សេវាស្តារនីតិសម្បទា របបសន្តិសុខសង្គម នៅប្រទេសវៀតណាម (VSS) ។

ក្នុងកំឡុងពេលនៃការបំពេញទស្សនកិច្ចសិក្សាខាងលើនេះ មន្ត្រីជំនាញ នៃបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) បានផ្លាស់ប្តូរបទពិសោធន៍ការងារ តាមរយៈការពិភាក្សាជាមួយអង្គភាពផ្តល់សេវាស្តារនីតិសម្បទាមួយចំនួននៅប្រទេសវៀតណាមរួមមាន៖ អង្គភាពសន្តិសុខសង្គមវៀតណាម (Vietnam Social Security) ក្រសួងការងារ អតីតយុទ្ធជន និងសង្គមកិច្ច (Ministry of Labour Invalids and Social Affairs) វិទ្យាស្ថានជាតិសុខភាពវិជ្ជាជីវៈ និងបរិស្ថាន (National Institute of Occupational and Environ-mental Health) សាខាអង្គភាពសន្តិសុខសង្គមខេត្តគ្វ័ងនីញ និងមន្ទីរពេទ្យស្តារលទ្ធភាពពលកម្ម ខេត្តគ្វ័ងនីញ។ បន្ទាប់ពីបានជួបពិភាក្សាការងារជាមួយអង្គភាពពាក់ព័ន្ធនិងការផ្តល់សេវាស្តារនីតិសម្បទា ជាបន្តបន្ទាប់មកមន្ត្រីការិយាល័យស្តារនីតិសម្បទា នៃបេឡាជាតិរបបសន្តិសុខសង្គម បានទទួលនូវបទពិសោធន៍ការងារថ្មីៗ មួយចំនួនស្តីពីការផ្តល់សេវាស្តារនីតិសម្បទា របស់របបសន្តិសុខសង្គមវៀតណាម (VSS) ដែលជាមូលដ្ឋាននៃចំណេះដឹងដ៏សំខាន់ៗ ល្អៗបន្ថែមទៀត សម្រាប់អភិវឌ្ឍន៍ការផ្តល់សេវាស្តារនីតិសម្បទារបស់បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) នៅកម្ពុជាឱ្យបានកាន់តែល្អប្រសើរ ។

ជាមួយគ្នានោះផងដែរ អង្គភាពនីមួយៗរបស់ប្រទេសវៀតណាម និងក្រុមការងារស្តារនីតិសម្បទា នៃបេឡាជាតិរបបសន្តិសុខសង្គម បានសន្យានឹងបន្តកិច្ចសហប្រតិបត្តិការគ្នា ក្នុងការចែករំលែកបទពិសោធន៍ថ្មីៗបន្ថែមទៀតពាក់ព័ន្ធទៅនឹងការផ្តល់សេវាស្តារនីតិសម្បទានេះ។

សូមបញ្ជាក់ថា ដំណើរទស្សនកិច្ចសិក្សានេះ មានរយៈពេលចំនួន ៥ថ្ងៃ គឺចាប់ពីថ្ងៃអង្គារ ៣រោច ខែពិសាខ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៩ រហូតដល់ថ្ងៃអាទិត្យ ៧រោច ខែពិសាខ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៩ ស្ថិតនៅទីក្រុងហាណូយ នៃប្រទេសវៀតណាម ៕



# កិច្ចប្រជុំក្រុមការងារបច្ចេកទេស SPIN ស្តីពីការធ្វើបទបង្ហាញលើរបាយការណ៍ នៃកិច្ចសម្ភាសន៍ការិយាល័យជំនាញ នៃ ប.ស.ស និងពិភាក្សាអំពីការអនុវត្តការងារបន្តរបស់ក្រុមការងារបច្ចេកទេស

នៅថ្ងៃសុក្រ ៦រោច ខែពិសាខ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៩ ក្រុមការងារបច្ចេកទេស នៃបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដឹកនាំដោយ **ឯកឧត្តម ហេង សុផាន់ណារិទ្ធ** ប្រធានការិយាល័យគោលនយោបាយ និងជាប្រធានក្រុមការងារបច្ចេកទេស បានរៀបចំកិច្ចប្រជុំមួយ ស្តីពីការធ្វើបទបង្ហាញលើរបាយការណ៍ នៃកិច្ចសម្ភាសន៍ការិយាល័យជំនាញ នៃ ប.ស.ស និងពិភាក្សាអំពីការអនុវត្តការងារបន្តរបស់ក្រុមការងារបច្ចេកទេស ដែលប្រព្រឹត្តទៅនៅសាលប្រជុំស្នាក់ការកណ្តាល នៃ ប.ស.ស រាជធានីភ្នំពេញ។





គោលបំណងនៃកិច្ចប្រជុំខាងលើនេះ គឺផ្តោតសំខាន់ទៅលើចំណុចសំខាន់ចំនួន២ គឺ៖

- ចែករំលែកបទពិសោធន៍ ស្តីអំពីនីតិវិធីរបស់ ប.ស.ស ដែលត្រូវបានចុះបញ្ជីក្រុមគោលដៅក្នុងការទទួលបានប័ណ្ណមូលនិធិសមធម៌សុខាភិបាល និងពិនិត្យឡើងវិញនូវបែបបទ យន្តការការកំណត់អត្តសញ្ញាណនៃការចុះបញ្ជិកា និងការប្រមូលភាគទានក្នុងរបបថែទាំសុខភាព។

- ស្តីពីជម្រើសដែលមានសក្តានុពល ដើម្បីសម្រួលដល់នីតិវិធីដែលមានវិសាលភាពលើក្រុមអ្នករត់ម៉ូតូកង់បី និងអ្នកធ្វើ-ការតាមផ្ទះស្ថិតក្រោមរបបរបស់ ប.ស.ស. ។

សូមបញ្ជាក់ថា កិច្ចប្រជុំនេះ មានការចូលរួមពី លោកស្រី Camille Vautier នាយកគម្រោងកិច្ចគាំពារសុខភាពសង្គមនៃអង្គការ Gret តំណាងសមាគមកិច្ចគាំពារសុខភាពសង្គមព្រមទាំងលោក លោកស្រី ជាមន្ត្រី ប.ស.ស ជាច្រើនទៀត ៕









# កូនមាសឪពុក

**កូនត្រូវ**ហាត់ធ្វើខ្លួនឱ្យសុភាពរាបសា មានការព្យាយាម ចេះអើពើជួយធ្វើការអ្នកដទៃដោយសេចក្ដីពេញចិត្តនិងធ្វើខ្លួនឱ្យជាមនុស្សបានការ ដើម្បីជាប់ជាឧបនិស្ស័យដល់ ធំឡើងកូនបាន ធ្វើជាមនុស្សល្អ ជាមនុស្សមានសេចក្ដី ចម្រើនមាំទាំក្នុងជីវិត។

**កូននៅតូច** កូនធ្វើអ្វីត្រូវឱ្យនៅក្នុងហ្វឹកហាត់កសាងខ្លួន បើកូន មាន ស្មារ តីក សាង ខ្លួន ជានិច្ចនោះ កូនធ្វើអ្វីៗតែង មានរបៀបរៀបរយ កាលបើមានរបៀបរៀបរយល្អហើយ កូនអាចរៀនសូត្រនិងធ្វើការងារផ្សេងៗបានដោយត្រឹមត្រូវ តទៅកូននឹងបានជាមនុស្សមាននូវសេចក្ដីសម្រេចនិងសេចក្ដីចម្រើនឱ្យដល់ខ្លួនឯងព្រមទាំងសង្គមគ្រួសារសង្គមជាតិក្នុងអនាគតយ៉ាងពិតប្រាកដ។

**កូនត្រូវ**តែជាមនុស្សល្អដូចតទៅ៖ជាកូនដែលល្អរបស់ឪពុកម្ដាយ  ជាសិស្សដែលល្អរបស់គ្រូអាចារ្យ ជាមិត្តដែលល្អរបស់មិត្ត ជាប្រជាពលរដ្ឋល្អរបស់ប្រទេសជាតិ ជាសាវ័កល្អរបស់ព្រះសម្មាសម្ពុទ្ធ។ ចូរកូនមានជីវិតត្រឹមត្រូវនៅក្នុងលោកនេះដោយខំប្រឹង សាងនូវសុចរិតពិតប្រាកដ ចូរកូនរស់នៅឱ្យបានជាក្ដីសង្ឃឹមរបស់មនុស្សទាំងឡាយ ចូរកូនប្រាថ្នាឱ្យពិភពលោកបានជួបនូវសេចក្ដីសុខស្ងប់។

**កូនត្រូវ**ដឹងថា ៖ធម៌រមែងរក្សាឱ្យយើងមានសេចក្ដីសុខ តែធម៌ នឹងមករក្សាយើងមិនបានឡើយ បើយើងមិនចូលទៅរកធម៌ទេ នោះ ប្រៀបដូចជាអាហារ នឹងមកឱ្យយើងឆ្អែតមិនបានដោយពិត បើយើងមិនទៅបរិភោគនូវអាហារនោះៗទេយ៉ាងណាមិញ ធម៌ក៏យ៉ាងនោះដែរ បើយើងមិនយកមកបដិបត្តិទេ ធម៌ក៏ជួយអ្វីយើង មិនបានឡើយ ដូច្នេះ ក្នុងការដែលយើងនឹងមាននូវសេចក្ដីសុខ សេចក្ដីចម្រើនទៅបាននោះ ក៏ព្រោះតែយើងបានបដិបត្តិនូវធម៌ ហ្នឹងឯង។

**ធម៌**ជារបស់ចាំបាច់ក្រៃលែងជាងអាហារ ក្រៃលែងជាងខ្យល់ អាកាស និងក្រៃលែងជាងអ្វីៗទាំងអស់ ព្រោះធម៌ធ្វើឱ្យជីវិត យើងមានគុណតម្លៃ។ ជីវិតរបស់ឪពុកតាំងពីមានកូនរហូតមកដល់ខណៈនេះ សេចក្ដីប្រាថ្នារបស់ឪពុកដែលមានចំពោះកូនគឺ សូមឱ្យ កូនមានការចេះដឹងល្អ និងមានការប្រព្រឹត្តល្អ។

**ទ្រព្យសម្បត្តិ**មិនមែនជារបស់សំខាន់ខ្លាំងណាស់ទេក្នុងការដែលឪពុកម្ដាយចែកឱ្យកូននោះ តែការចេះដឹងល្អនិងការប្រព្រឹត្តល្អ ជាសម្បត្តិសំខាន់ដ៏ក្រៃលែងដែលឪពុកនិងម្ដាយប្រាថ្នាប្រគល់ឱ្យដល់កូនជាទីស្រឡាញ់ និងជាទីហួងហែងរហូតមក។បើកូនធ្វើតាមពាក្យដែលឪពុកនិងម្ដាយណែនាំផលនឹងកើតបានជាគុណតម្លៃនិងជាសេចក្ដីសុខឱ្យដល់កូនរួមទាំងគ្រួសារព្រមទាំងអ្នកដែលនៅជុំវិញកូនទៀតផង៕



# ចេក ងាយរកនិងមានតម្លៃសមរម្យប៉ុន្តែផ្តល់អត្ថប្រយោជន៍មហាសាលចំពោះសុខភាព

ក្រៅពីមានរសជាតិឆ្ងាញ់ហើយនោះ ផ្លែចេកក៏មានផ្ទុកសម្បូរទៅដោយជាតិប៉ូតាស្យូម រួមទាំងសារធាតុចិញ្ចឹមជាច្រើនផ្សេងទៀតដែលល្អសម្រាប់រក្សាសុខភាពរាងកាយ។

ចេកក៏ជាជម្រើសនៃផ្លែឈើដ៏ប្រសើរសម្រាប់អ្នកចង់ស្រកទម្ងន់ផងដែរដោយវាមានផ្ទុកជាតិកាឡូរីទាប។ខាងក្រោមនឹងបង្ហាញពីអត្ថប្រយោជន៍គួរឱ្យភ្ញាក់ផ្អើលនៃការទទួលទានផ្លែចេកជាប្រចាំ៖

### ១. ទប់ស្កាត់ប្រឆាំងជំងឺខ្វះគ្រាប់ឈាមក្រហម

ចេកជាជម្រើសនៃផ្លែឈើដ៏ល្អបំផុតសម្រាប់អ្នកជំងឺខ្វះគ្រាប់ឈាមក្រហមដោយវាមានផ្ទុកសម្បូរទៅដោយជាតិដែកដែលជួយបង្កើនការផលិតកោសិកាគ្រាប់ឈាមក្រហម។

### ២. ពង្រឹងប្រព័ន្ធភាពស៊ាំរាងកាយ

ចេកក៏មានផ្ទុកសម្បូរទៅដោយវីតាមីន C ផងដែរហើយនេះជាហេតុផលដែលអ្នកគួរព្យាយាមទទួលទានផ្លែឈើនេះជាប្រចាំដើម្បីបង្កើនប្រព័ន្ធភាពស៊ាំនៃរាងកាយ។អ្នកនឹងសម្គាល់ឃើញលទ្ធផល ជាពិសេសកំឡុងពេលរដូវនៃជំងឺផ្ដាសាយ ឬរដូវត្រជាក់ចូលមកដល់។

### ៣. សុខភាពបេះដូង

ផ្លែចេកជាប្រភពដ៏ប្រសើរបំផុតនៃជាតិប៉ូតាស្យូម និងម៉ង់កាណែស ដែលចាំបាច់សម្រាប់រក្សាសុខភាពបេះដូង ជាពិសេសជួយគ្រប់គ្រងសម្ពាធឈាមទប់ស្កាត់ជំងឺគួរឱ្យព្រួយបារម្ភបានជាច្រើន។

### ៤. គ្រប់គ្រងសម្ពាធឈាម

ផ្លែចេក ក៏ជាប្រភពដ៏ល្អបំផុតមួយ នៃប៉ូតាស្យូម និងម៉ាញ៉េស្យូម ដែលមានប្រសិទ្ធិភាពជួយគ្រប់គ្រងជាតិសូដ្យូមទប់ស្កាត់បញ្ហាសម្ពាធឈាមឡើងខ្ពស់ព្រមទាំងធ្វើឱ្យកម្រិតនៃសម្ពាធឈាមមានលក្ខណៈប្រសើរឡើងផងដែរ។

### ៥. បង្កើនការរំលាយអាហារ

ផ្លែចេកមានផ្ទុកសម្បូរទៅដោយជាតិសសៃដែលជួយកម្រិតល្បឿនត្រឹមត្រូវនៃការរំលាយអាហារ។ការទទួលទានចេកត្រឹមតែមួយផ្លែនឹងធ្វើឱ្យអ្នកមានអារម្មណ៍ឆ្អែតបានយូរនិងថែមទាំងអាចជួយទប់ស្កាត់ដោះស្រាយបញ្ហាទល់លាមកទៀតផង។

### ៦. សុខភាពតម្រងនោម

ប៉ូតាស្យូមក៏សំខាន់សម្រាប់សុខភាពតម្រងនោមល្អប្រសើរផងដែរ។ដូច្នេះដើម្បីជៀសផុតពីហានិភ័យនៃជំងឺតម្រងនោម ចូរទទួលទានចេកឱ្យបានយ៉ាងហោចណាស់ពី ៤ ទៅ ៦ ដង ក្នុងមួយសប្តាហ៍។

### ៧. ព្យាបាលជំងឺហឺត

នោះក៏ព្រោះតែចេកគឺមានផ្ទុកសម្បូរទៅដោយជាតិប៉ូតាស្យូម ដែលនឹងជួយកាត់បន្ថយអាការៈនៃជំងឺហឺតបានយ៉ាងប្រសើរសម្រួលដល់ការដកដង្ហើម។

### ៨. ជួយឱ្យស្រកទម្ងន់

ចេកក៏ជាជម្រើសនៃផ្លែឈើដ៏ប្រសើរសម្រាប់អ្នកចង់ស្រកទម្ងន់ផងដែរដោយវាមានផ្ទុកជាតិកាឡូរីទាប ប៉ុន្តែសារធាតុចិញ្ចឹមសំខាន់ៗខ្ពស់។លើសពីនេះទៅទៀតផ្លែចេកមានផ្ទុកសម្បូរទៅដោយជាតិសរសៃដែលជួយកម្រិតល្បឿនត្រឹមត្រូវនៃការរំលាយអាហារ។ ការទទួលទានចេកត្រឹមតែមួយផ្លែនឹងធ្វើឱ្យអ្នកមានអារម្មណ៍ឆ្អែតបានយូរនិងថែមទាំងអាចជួយទប់ស្កាត់ដោះស្រាយបញ្ហាទល់លាមកទៀតផង។

### ៩. សុខភាពស្បែក

មានផ្ទុកសម្បូរទៅដោយជាតិប៉ូតាស្យូម វីតាមីន C និង វីតាមីនB6 ដែលចាំបាច់ក្នុងការរក្សាគុណភាពនៃជាតិសំណើមរបស់ស្បែក។ ក្នុងករណីខ្លះគឺស្បែកស្ងួតបណ្តាលមកពីកង្វះនៃជាតិប៉ូតាស្យូម។ ដូច្នេះព្យាយាមរួមបញ្ចូលផ្លែចេកក្នុងរបបអាហារប្រចាំថ្ងៃរបស់អ្នក។ អ្នកក៏អាចកិនសាច់ចេកឱ្យម៉ដ្ឋខាប់រួចលាបវាលើមុខ ហើយទុកចោលសម្រាប់រយៈពេលពី ២០ ទៅ ៣០ នាទី សឹមលាងសម្អាតចេញជាការស្រេច។

### ១០. កាត់បន្ថយហានិភ័យនៃជំងឺមហារីក

ផ្លែចេកក៏មានផ្ទុកសម្បូរទៅដោយវីតាមីន C ដែលជាសារធាតុប្រឆាំងអុកស៊ីតកម្មដ៏មានឥទ្ធិពលជួយការពារកោសិកា និង DNA  ពីការបំផ្លាញនៃរ៉ាឌីកាល់សេរី។ លើសពីនេះទៅទៀតចេកក៏ជាប្រភពដ៏ល្អបំផុតមួយនៃជាតិសរសៃដែលអាចជួយទប់ស្កាត់ហានិភ័យនៃជំងឺមហារីកពោះវៀនធំបានយ៉ាងប្រសើរ៕

ប្រភព៖ https://www.health.com.kh







០២៣ ៨៨ ២៤ ៣៤
០២៣ ៩៩ ៨៤ ១៧
០២៣ ៩៩ ៨៤ ១៨
០២៣ ៩៩ ៨៨ ១៩
០២៣ ៨៨ ២៦ ២៣

បេឡាជាតិរបបសន្តិសុខសង្គម
NSSF Official
www.nssf.gov.kh
info@nssf.gov.kh

អាគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
(បរិវេណក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ)